សេចក្តីថ្លែងការណ៍

ភ្នំពេញ ថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០១១

ម.ស.ម.ក ចេញសៀវភៅសង្ខេប (សម្រាប់អ្នកស្ម័គ្រចិត្ត និងអ្នកពាក់ព័ន្ធ) ស្តីអំពីសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងការកាត់បន្ថយលំហសង្គមស៊ីវិលនៅកម្ពុជា

ថ្ងៃនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា បានចេញសៀវភៅសង្ខេបមួយដែលមានចំណងជើងថា "សៀវភៅសង្ខេបសម្រាប់ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធ អំពីសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងការកាត់បន្ថយលំហសង្គមស៊ីវិលនៅកម្ពុជា"។

សៀវភៅសង្ខេបនេះ ធ្វើការពិភាក្សាចំពោះការគំរាមគំហែងមកលើលំហសង្គមស៊ីវិល និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដែលកំពុងប្រឈមមុខជាមួយសកម្មភាពរបស់ភ្នាក់ងារនៃរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន និងភាពចម្រូងចម្រាស់ក្នុង សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ជាចម្បងសៀវភៅសង្ខេបនេះផ្តោតលើ ៖ (១) កិច្ចខិតខំប្រឹងប្រែងបន្តបន្ទាប់ដើម្បីបំបិទមាត់ដល់អង្គការមិនមែនរដ្ឋាភិបាល និងមតិជំទាស់ និងភាពសឹករិចរិលនៃលំហលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា (២) កង្វះខាតមូលដ្ឋានក្នុងសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំខាន់ជាងនេះទៀតគឺ (៣) ការអនុវត្តច្បាប់ដោយមិនត្រឹមត្រូវពោលគឺ (សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល) ប្រសិនបើយោងតាមស្ថានភាពបច្ចុប្បន្ន។ ចំពោះសេចក្តីសន្និដ្ឋាន គឺគ្រោះថ្នាក់ដែលសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដាក់មកលើសង្គមស៊ីវិល និងកម្មវិធីរបស់ម្ចាស់ជំនួយ យោងតាមព្រឹត្តិការណ៍ថ្មីៗនេះ ហើយបានចងក្រងជាឯកសារក្នុងឧបសម្ព័ន្ធរបស់សៀវភៅសង្ខេបនេះ ដែលអាចរកអានបាននៅលើ Sithi: www.sithi.org/annex_view.php ដែលជា គេហទំព័រសិទ្ធិមនុស្សកម្ពុជា ដែលបានទទួលរង្វាន់ គ្រប់គ្រងដោយ ម.ស.ម.ក ។

ទោះបីជា សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះ បានកែលម្អក៏ដោយ តែវិសោធនកម្មទាំងនោះ មិនបានលុបបំបាត់គ្រោះថ្នាក់ដែលច្បាប់នេះអាចបង្កឲ្យមាននោះទេ។ សេចក្តីថ្លែងការណ៍ របស់រដ្ឋាភិបាលអំពីរបៀបដែលច្បាប់នេះនឹងត្រូវអនុវត្ត និង "នរណាខ្លះដែលគួរខ្លាច បានបញ្ជាក់ថាច្បាប់នេះនឹងត្រូវប្រើដើម្បីបង្ក្រាបក្រុមអង្គការតស៊ូមតិទាំងឡាយ ដែលថ្កោលទោសឲ្យរដ្ឋាភិបាលត្រូវទទួលខុសត្រូវ។ ព្រឹត្តិការណ៍ថ្មីៗនេះ បានបង្ហាញថាប្រសិនបើមានការខ្វះខាតផ្នែកនីតិវិធីត្រឹមតែបន្តិច ទោះជាក្នុងការពិត ឬការស្រមើស្រមៃ ចំណុចទាំងនោះអាច និងត្រូវបានប្រើដើម្បីបំបិទមាត់អ្នករិះគន់រដ្ឋាភិបាល។

ប៉ុន្តែ អ្វីដែលសំខាន់គឺ សេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនមែនជាបញ្ហាចម្បងទេ។ ទោះបីជា រដ្ឋាភិបាលមិនបានកែប្រែសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល តាមអនុសាសន៍ និងការណែនាំដើមរបស់សង្គមស៊ីវិល និងម្ចាស់ជំនួយក៏ដោយ ប៉ុន្តែសកម្មភាពថ្មីៗរបស់រដ្ឋាភិបាលបានបង្ហាញថា ការព្រួយបារម្ភដ៏សំខាន់នោះគឺ ការរឹតបន្តឹងជាបន្តបន្ទាប់ និងយ៉ាងឆាប់រហ័ស

របស់រដ្ឋាភិបាលមកលើលំហសិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងគោលបំណងរបស់រដ្ឋាភិបាលក្នុងការត្រួតត្រាទាំងស្រុងមកលើសង្គមស៊ីវិល និងការបង្កឲ្យមានភាពខ្វះខាតដល់អ្នកពាក់ព័ន្ធផ្សេងៗ ទៅវិញទេ។ ប្រសិនបើចំណុចនេះកើតឡើង ផលវិបាកអវិជ្ជមានដ៏ច្រើនលើសលប់នឹងបង្កឲ្យមាន ៖ កាត់បន្ថយការផ្តល់ជំនួយដល់ប្រជាពលរដ្ឋកម្ពុជាដែលត្រូវការបំផុត ការធ្លាក់ចុះដុនដាបនៃស្ថានភាពសិទ្ធិមនុស្ស កំណើនអំពើពុករលួយ បាត់បង់ឱកាសវិនិយោគទុនពីបស្ចិមប្រទេស និងបាត់បង់ឥទ្ធិពលរបស់បស្ចិមប្រទេស។

បទពិសោធន៍ថ្មីរបស់ធនាគារពិភពលោក បង្ហាញឲ្យឃើញថា ប្រសិនបើម្ចាស់ជំនួយចាត់វិធានការម៉ឺង-ម៉ាត់ នឹងមានឱកាសជាច្រើនដែលពួកគេអាចជះឥទ្ធិពលលើរដ្ឋាភិបាល។ ម្ចាស់ជំនួយត្រូវតែប្រើមូលនិធិ និងឥទ្ធិពលរបស់ខ្លួនដើម្បី ធានាដល់ការរស់រានរបស់សង្គមស៊ីវិល និងលំហសិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

-ចប់-

លោកអ្នកអាចរកអាន និងទាញទុកជាភាសារអង់គ្លេស និងភាសាខ្មែរនូវសៀវភៅសង្ខេបនេះនៅលើគេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា www.sithi.org និងនៅលើវេបសាយរបស់ ម.ស.ម.ក www.cchrcambodia.org ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងតាមរយៈអ៊ីម៉ែលរបស់ ម.ស.ម.ក. info@cchrcambodia.org
សូមបញ្ជាក់ថា សេចក្តីថ្លែងការណ៍ដែលបានភ្ជាប់មកនេះគឺនៅក្នុងទម្រង់ជា PDF ។

<u>បណ្ណាធិការ</u>

ម.ស.ម.ក ត្រូវបានបង្កើតឡើងនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០០២។

ម.ស.ម.ក គឺជាសមាជិករបស់ ដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អ៊ីហ្វិក) ដែលជាបណ្តាញសកលដើម្បីការបញ្ចេញមតិដោយសេរី។

គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានរង្វាន់ប្រចាំឆ្នាំ២០១១របស់មូលនិធិនៃការបង្កើតថ្មីសម្រាប់សង្គមព័ត៌មានវិទ្យា ក្នុងចំណាត់ថ្នាក់នៃ សិទ្ធិ និងសេរីភាព។